# ការធ្វើ តេស្ត COVID ទៅកាន់សិស្សនឹងផ្អាកចោលសិន

ជម្រាបជូនសហគមន៍សាលារៀន ឡុងប៊ីច,

ឆមាសនៃរដូវស្លឹកឈើធ្លាក់បាននាំមកលទ្ធផលជោគជ័យអំពីការបើកសាលារៀនឡើងវិញសម្រាប់សិស្សចូលរៀនផ្ទាល់ ដែលបណ្តាលច្រើនជាងគេមកពីកិច្ចការបានបំពេញរួមគ្នាជាក្រុមនៃសិស្ស មាតាបិតា បុគ្គលិក និង ក្រសួងផ្សេងៗជាដៃគូ ។ ដូចលោកអ្នកនៅចងចាំហើយ គឺថា យើងបានចាប់ផ្តើមឆ្នាំសិក្សា ដោយធ្វើ តេស្ត COVID-19 ជាលក្ខណៈមិនបង្ហាញរោគសញ្ញាជាងចំនួន 60,000 ដង ទៅកាន់សិស្ស ដែលនាំមកជាលទ្ធផល វិជ្ជមាន ក្រោមកម្រិត 1% ។ នៅពាក់កណ្តាលខែកញ្ញា យើងបានកែប្រែការធ្វើ តេស្ត ឡើងវិញ ដោយប្រើត្រឹមតែ 10% ប៉ុណ្ណោះនៃចំនួនសិស្សនៅតាមសាលារៀននិមួយៗ ។ សរុបទៅ គឺយើងបានធ្វើ តេស្ត COVID-19 លើសជាងចំនួន 116,000 ដង តាំងពីចាប់ផ្តើមឆ្នាំសិក្សាមក ហើយការបង្ហាញជាលទ្ធផល វិជ្ជមាន គឺមានភាពយ៉ាងទៀងទាត់ក្រោមកម្រិត 1% ។

ការធ្វើ តេស្ត ជាលក្ខណៈមិនបង្ហាញរោគសញ្ញា គឺជាមធ្យោបាយស្ទង់វាស់ម្យ៉ាងក្នុងចំណោមមធ្យោបាយផ្សេងៗទៀត ដែលកំពុងចាត់ចែងសម្រាប់គ្រប់គ្រងមកលើជម្ងឺ COVID-19 ដែលអាចកើតរាលដាលបាននៅក្នុងសាលារៀនរបស់យើង ។ យើងនៅតែបន្តការប្រើតាមពិធីការ COVID-19 ជាច្រើនចំណែក ដើម្បីរក្សាសុវត្ថិភាព ដូចជាៈ ពាក់គម្របមុខ, ឆែកមើលរោគសញ្ញា, ចំណាយពេលសម្រាកនៅផ្ទះ បើសិនជាឈឺ, កែតម្លើងម៉ាស៊ីនបញ្ចេញខ្យល់ចេញចូល, រក្សាការជូតសំអាតដៃ, បង្ហាញជារបាយការណ៍, ធ្វើការតាមដានអំពីមនុស្សផ្សេងៗ ដែលបានចំណាយពេលនៅក្បែរ និង បើសិនចាំបាច់ គឺឃាត់ទុកឱ្យនៅផ្ទះមួយរយៈពេលសិន ។

ដោយស្របតាមមូលហេតុ ដែលប៉ះពាល់មកលើលទ្ធផល វិជ្ជមាន ជាកម្រិតទាបនៅតាមសាលារៀនរបស់យើង គឺយើងនឹងផ្អាកចោលសិនអំពីការធ្វើ តេស្ត ជាលក្ខណៈមិនបង្ហាញរោគសញ្ញាទៅកាន់ 10% នៃចំនួនសិស្សនៅតាមសាលារៀននិមួយៗ ចាប់ផ្តើមពីថ្ងៃចន្ទ ទី15 ខែវិច្ឆិកា ខាងមុខនេះទៅ និង បន្តធ្វើរហូតទៅដល់យ៉ាងតិចចុងពេលសម្រាកនៃរដូវរងា ។ យើងបានធ្វើ តេស្ត ជារបៀបនេះ ដែលចាត់ទុកជាការប្រុងប្រយ័ត្នជាបន្ថែមនៅក្នុងប៉ុន្មានសប្តាហ៍ជាពេលដំបូងនៃឆ្នាំសិក្សា ប៉ុន្តែ វាគ្មានការតម្រូវឱ្យធ្វើតាមនោះទេ ។ ក្រសួងអប់រំ ឌីស្រ្ទីគ ភាគច្រើនឈប់ប្រើតាមការធ្វើ តេស្ត ជារបៀបនេះទៀតហើយ ។ សូមចំណាំថា កីឡាករ និង បុគ្គលិកប្រចាំក្រសួងអប់រំ LBUSD នឹងនៅតែទទួលការសុំតម្រូវឱ្យធ្វើ តេស្ត យោងទៅតាមឋានៈនៃការចាក់ថ្នាំ ។

ដូចលោកអ្នកបានជ្រាបមកហើយ គឺថា ក្នុងពេលឥឡូវនេះ ក្រសួងអប់រំ ឌីស្ត្រីគ របស់យើងគ្មានច្បាប់បញ្ជាអ្វីទេសម្រាប់តម្រូវឱ្យសិស្សទទួលការចាក់ថ្នាំបង្ការជម្ងឺ COVID-19 ។ យ៉ាងណាក៏ដោយ ក៏យើងនៅតែសុំជម្រុញដល់មនុស្សម្នាទាំងអស់ ដែលមានអាយុត្រឹមត្រូវ និង សមត្ថភាពមាំមួន ឱ្យទៅទទួលការចាក់ថ្នាំបង្ការជម្ងឺ ។ ក្នុងពេលថ្មីៗនេះ ការចាក់ថ្នាំបង្ការជម្ងឺ COVID-19 គឺមានសម្រាប់ផ្តល់ទៅកាន់ក្មេងអាយុ 5 ទៅ 11 ឆ្នាំ ហើយ[បញ្ជីរាយឈ្មោះនៃមន្ទីរ គ្លីនិក សម្រាប់ជាកន្លែងទៅចាក់ថ្នាំ ដែលទទួលការផ្គត់ផ្គង់ពីក្រសួងសុខាភិបាលប្រចាំទីក្រុង ឡុងប៊ីច គឺមានបង្ហាញនៅទីនេះ] ។

ម្តងទៀត យើងសូមថ្លែងអំណរគុណទៅកាន់ការប្រឹងប្រែងដ៏អស្ចារ្យពីសហគមន៍ ដែលបានជួយយើងក្នុងការបញ្ជូនសិស្សត្រឡប់ចូលរៀននៅតាមថ្នាក់វិញក្នុងរដូវស្លឹកឈើធ្លាក់ ។

ដោយអំណរគុណដ៏ជ្រៅជ្រះ,

Jill

Jill A. Baker, Ed. D.